ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បណ្តឹង/សំណុំរឿង
លេខ ០៧១ ០៧២ ០៧៣ ០៧៤ ០៧៥
ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧

សេចក្តីសម្រេច
លេខ ០២០
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញបទបញ្ជាផ្ទៃក្នុងលេខ ១១៩៤/១២ គ.ជ.ប ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៦១/១៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតឆ្នាំ២០១៦
- បានឃើញពាក្យបណ្តឹង/សំណុំរឿងលេខ ០៧១ ០៧២ ០៧៣ ០៧៤ និង ០៧៥ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ របស់លោក ហ៊ាង ចិន្តា ប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេចនៃសង្កាត់ច្បារអំពៅទី២
- បានឃើញសេចក្តីសម្រេចលេខ ០០៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ និងគណៈលេខាធិការសេវានាការ
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ របស់លោក ហ៊ាង ចិន្តា ផ្ទេរសិទ្ធិជូនលោក កាក់ កុម្ភារ ដើម្បីធ្វើជាអ្នកតំណាង
- បានឃើញលិខិតផ្ទេរសិទ្ធិ និងពឹងពាក់មេធាវី ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់លោក ឃុន វុធ ផ្ទេរសិទ្ធិ និងពឹងពាក់លោកមេធាវី គឹម វាសនា ដើម្បីធ្វើជាមេធាវីតំណាង និងការពារ

- **ក្រោយពីបានស្តាប់ចម្លើយរបស់ចុងចម្លើយ**
- **ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងក្រុមប្រឹក្សាសង្កាត់**
- **ក្រោយពីបានពិនិត្យភស្តុតាង**
- **ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ និងបទបញ្ជា និងនីតិវិធីហើយ**

- **យល់ឃើញថា** លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ របស់លោក ហ៊ាង ចិន្តា ផ្ទេរសិទ្ធិជូនលោក កាក់ កុម្ភារ ធ្វើជាតំណាងក្នុងការចូលរួមសវនាការនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់។
- **យល់ឃើញថា** លិខិតផ្ទេរសិទ្ធិ និងពឹងពាក់មេធាវី ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់លោក ឃុន វុធ ផ្ទេរសិទ្ធិ និងពឹងពាក់លោកមេធាវី គឹម វាសនា ធ្វើជាមេធាវីតំណាង និងការពារក្នុងសវនាការនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់។
- **យល់ឃើញថា** ពាក្យបណ្តឹងរបស់លោក ហ៊ាង ចិន្តា ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ ជំទាស់នឹងសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេចនៃសង្កាត់ច្បារអំពៅទី២ ចំនួន ៥ បណ្តឹង ធ្វើឡើងក្នុងកំណត់ច្បាប់ស្របតាមមាត្រា ៦២ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុច ៥.៣.១០.២ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ដែលអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះលើកយកមកពិចារណា និងធ្វើការសម្រេចបាន។
- **យល់ឃើញថា** សំណុំរឿងលេខ ០៧១ ០៧២ ០៧៣ ០៧៤ និង ០៧៥ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ មានដើមបណ្តឹងលោក ហ៊ាង ចិន្តា ប្តឹងសុំលុបឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតចេញពីបញ្ជីបោះឆ្នោតដំបូងនៃសង្កាត់ច្បារអំពៅទី២ តែមួយដូចគ្នា គប្បីក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណាលើការបញ្ចូលសំណុំរឿងទាំង ៥ ទៅជាសំណុំរឿងតែមួយ។
- **យល់ឃើញថា** នាពេលសវនាការដើមបណ្តឹង និងតំណាងដើមបណ្តឹងអវត្តមាន មិនមានអំណះអំណាង និងការផ្តល់ភស្តុតាងអ្វីថ្មីជូនក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណានោះឡើយ។
- **យល់ឃើញថា** តាមការពិនិត្យពាក្យបណ្តឹង និងការអានចម្លើយរបស់លោក ហ៊ាង ចិន្តា ជាដើមបណ្តឹងឃើញថា ដើមបណ្តឹងប្តឹងសុំលុបឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតចំនួន ១៤៩ នាក់ សរុបទាំង ៥ សំណុំរឿង ចេញពីបញ្ជីបោះឆ្នោតដំបូងនៃសង្កាត់ច្បារអំពៅទី២ ដោយសំអាងលើអ្នកចុះឈ្មោះបោះឆ្នោតទាំងនោះ គឺសុទ្ធតែជាជនជាតិវៀតណាម កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតែមិនមានព្រះរាជក្រឹត្យដែលផ្ទុយនឹងមាត្រា២៦ នៃច្បាប់ស្តីពីសញ្ជាតិ ហើយអ្នកទាំងនោះមានសំនៀងជាជនជាតិវៀតណាម មិនចេះសរសេរ មិនចេះអានអក្សរខ្មែរ និងមានសម្លៀកបំពាក់ជាជនជាតិវៀតណាម មានការរៀបចំសែនរបៀបជាជនជាតិវៀតណាម។ ហើយក្រុមប្រឹក្សាសង្កាត់ច្បារអំពៅទី២ បែរជាមិនយកមកពិចារណា ដោយសម្រេចរក្សាឈ្មោះអ្នកទាំង ១៤៩ នាក់ក្នុងបញ្ជីបោះឆ្នោតតែម្តង។ ក្នុងរឿងនេះ ខ្លួនសូមឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិចារណាលុបចេញពីបញ្ជីបោះឆ្នោត។
- **យល់ឃើញថា** ការឆ្លើយបំភ្លឺរបស់ឈ្មោះ ពៅ អេង ឈ្មោះ រស់ វណ្ណា ឈ្មោះ ម៉ុក លាង ឈ្មោះ ចៅ ង៉ា និងឈ្មោះ គឹម ហាមប៊ីណា បានឆ្លើយប្រហាក់ប្រហែលគ្នានាពេលសវនាការថា ពួកខ្លួនមិនមែនជាជនជាតិវៀតណាមទេ ខ្លួនបានចុះឈ្មោះបោះឆ្នោតដោយប្រើប្រាស់ឯកសារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ បណ្ណបោះឆ្នោតសម័យអ៊ុនតាក់ ដូចបានបង្ហាញជូនក្រុមប្រឹក្សាជំនុំជម្រះនាពេលនេះ។ ឈ្មោះ ពៅ អេង ក៏បានបញ្ជាក់ផងដែរថា កុំថាខ្លួនជាជនជាតិវៀតណាម សូម្បីតែឮតែឈ្មោះវៀតណាមខ្លួនខឹងទៅហើយ ហើយយួនជេរខ្លួនក៏ខ្លួនមិនដឹងដែរ ខ្លួនមានឪពុកម្តាយជាខ្មែរសុទ្ធសាធ។ ក្នុងរឿងនេះ ពួកខ្លួនសុំរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតដដែល។

- **យល់ឃើញថា** ការធ្វើសន្និដ្ឋានរបស់លោកមេធាវី គឹម វាសនា នាពេលសវនាការថា ផ្អែកលើដើមបណ្តឹងនិងសាក្សីអវត្តមាន ខ្លួនកត់សម្គាល់ឃើញថា ឈ្មោះ ហ៊ាង ចិន្តា ទើបមានអាយុ ២០ ឆ្នាំ ហើយអ្នកដែលត្រូវឈ្មោះ ហ៊ាង ចិន្តា ប្តឹងនោះមានអាយុ ៦០ ឆ្នាំជាង ហើយអ្នកទាំងហ្នឹងសុទ្ធតែមានឯកសារត្រឹមត្រូវលក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោត ស្របតាមច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្នុងនាមជាមេធាវីការពារឱ្យក្រុមប្រឹក្សាសង្កាត់ច្បារអំពៅទី២ ខ្ញុំសូមរក្សាទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់ច្បារអំពៅទី២ ទុកជាបានការ ដោយរក្សាទុកអ្នកចុះឈ្មោះបោះឆ្នោតទាំងអស់ក្នុងបញ្ជីបោះឆ្នោតដដែល។
- **យល់ឃើញថា** តាមការពិនិត្យពាក្យបណ្តឹង និងការអានចម្លើយរបស់លោក ហ៊ាង ចិន្តា ជាដើមបណ្តឹង ដោយអះអាងថា ឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតចំនួន ១៨៩ នាក់ សរុបទាំង ៥ សំណុំរឿង ដោយសំអាងលើអ្នកចុះឈ្មោះបោះឆ្នោតទាំងនោះ គឺសុទ្ធតែជាជនជាតិវៀតណាម កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតែមិនមានព្រះរាជក្រឹត្យ មានសំនៀងជាជនជាតិវៀតណាម មិនចេះសរសេរ មិនចេះអាន អក្សរខ្មែរ និងមានសម្លៀកបំពាក់ជាជនជាតិវៀតណាម មានការរៀបចំសែនរបៀបជាជនជាតិវៀតណាម ហើយចាត់ទុកអ្នកទាំងនោះ ពុំមានសញ្ជាតិជាខ្មែរ ការលើកឡើងបែបនេះមិនមានមូលដ្ឋានភស្តុតាងគតិយុត្តដែលអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណាជឿបានឡើយ ដោយហេតុថា សញ្ជាតិរបស់បុគ្គលម្នាក់ៗ គេអាចសម្គាល់បានតាមរយៈលិខិតយថាភូតផ្លូវការចេញដោយអាជ្ញាធរមានសមត្ថកិច្ច។
- **យល់ឃើញថា** តាមការឆ្លើយបញ្ជាក់របស់លោក ឃិន វុធ ជាតំណាងក្រុមប្រឹក្សាសង្កាត់ច្បារអំពៅទី២ នាពេលសវនាការថា យោងលើឯកសារច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បើអ្នកចុះឈ្មោះមានឯកសារ បំពេញលក្ខខណ្ឌចុះឈ្មោះគ្រប់គ្រាន់ហើយ ទើបក្រុមប្រឹក្សាសង្កាត់សម្រេចរក្សាទុក ដោយមានភស្តុតាងដែលអ្នកចុះឈ្មោះបានបង្ហាញជូនក្រុមប្រឹក្សាជំនុំជម្រះនាពេលនេះ។ក្នុងរឿងនេះខ្លួនសុំរក្សាទុកឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតទាំង៥សំណុំរឿងក្នុងបញ្ជីបោះឆ្នោតដដែល។
- **យល់ឃើញថា** តាមការលើកឡើង និងការបង្ហាញឯកសាររបស់ចុងចម្លើយ និងការបញ្ជាក់របស់តំណាងក្រុមប្រឹក្សាសង្កាត់ច្បារអំពៅទី២ និងការសន្និដ្ឋានរបស់លោកមេធាវី គឹម វាសនា ឃើញថា មានការស៊ីចង្វាក់ទៅលើភស្តុតាងដែលអ្នកចុះឈ្មោះបោះឆ្នោតបានយកមកប្រើប្រាស់ក្នុងពេលចុះឈ្មោះបោះឆ្នោតដែលអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាជឿបាន។
- **យល់ឃើញថា** តាមការពិនិត្យ និងស្រាវជ្រាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈឯកសាររបស់ក្រុមចុះឈ្មោះបោះឆ្នោតសង្កាត់ច្បារអំពៅទី២ បញ្ជូនមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឃើញថា អ្នកចុះឈ្មោះបោះឆ្នោត ១ នាក់ បានប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និង ១៤៦ នាក់ប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយបានមកចុះឈ្មោះបោះឆ្នោតនៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត ស្របតាមអាត្រា៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងប្រការ ៤.៤ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦។
- **យល់ឃើញថា** សេចក្តីសម្រេចលេខ ០០២ ០០៨ ០០៩ ០១០ និង ០១១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់ច្បារអំពៅទី២ សម្រេចរក្សាទុកឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតទាំង ១៨៧ នាក់ ក្នុងបញ្ជីបោះឆ្នោតនៃសង្កាត់ច្បារអំពៅទី២ មានលក្ខណៈត្រឹមត្រូវទៅតាមផ្លូវច្បាប់ហើយ។

សម្រេច

១- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ របស់លោក ហ៊ាង ចិន្តា ផ្ទេរសិទ្ធិជូនលោក កាក់ កុម្ភារ ធ្វើជាតំណាង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និងពឹងពាក់មេធាវី ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់លោក ឃុន វុធ ផ្ទេរសិទ្ធិ និងពឹងពាក់លោកមេធាវី គឹម វាសនា ដើម្បីធ្វើជាមេធាវីតំណាង និងការពារ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

៣- បញ្ចូលសំណុំរឿងលេខ ០៧២ ០៧៣ ០៧៤ និង ០៧៥ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ ទៅក្នុងសំណុំរឿងលេខ ០៧១ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧។

៤- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់លោក ហ៊ាង ចិន្តា ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានទទួលនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

៥- តម្កល់សេចក្តីសម្រេចលេខ ០០២ ០០៨ ០០៩ ០១០ និង ០១១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់ច្បារអំពៅទី២ ទុកជាបានការពេញទាំងមូល។

៦- សេចក្តីសម្រេចនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ កំបាំងមុខដើមបណ្តឹង ចំពោះមុខចុងចម្លើយ ហើយបើកផ្លូវប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៧

ជ. ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

ប្រធាន

ស៊ិក ប៊ុនហុក